ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៥៥៣ "ន"

ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៥២

ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ ៣០១១

ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ ៤៣៦២

ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង៨ព្រឹក នៅសាលសវនាការទី៤ ដោយមានសមាសភាពជំនុំជម្រះ ៖

ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៥២ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ [redacted] អេងសួ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរសន្តិសុខនិងលេខាធិការសហជីពឯករាជ្យការពារកម្មករនៃក្រុមហ៊ុនហ្វីនិក ស៊ីឃ្យូរីធី ស៊ីស្ទឹម សាសនាព្រះពុទ្ធ ទីកន្លែងកំណើត [redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្នផ្ទះលេខ៥២ ផ្លូវលេខ ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប៊ុន "រស់" ម្តាយឈ្មោះ [redacted] ចាន់ថន "រស់" នៅលីវ ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។ (ក្រៅឃុំ)

-ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

២-ឈ្មោះ [redacted] ឃួរិន ភេទប្រុស អាយុ៥៤ឆ្នាំ ជនជាតិខ្មែរ មុខរបរសន្តិសុខនិងប្រធានសហជីពឯករាជ្យការពារកម្មករនៃក្រុមហ៊ុនហ្វីនិក ស៊ីឃ្យូរីធី ស៊ីស្ទឹម សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នផ្ទះលេខ៣តេ ផ្លូវលំ ភូមិជម្ពូវ័ន្ត សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឆាំ "រស់" ម្តាយឈ្មោះ [redacted] សុខ "រស់" ប្រពន្ធឈ្មោះ [redacted] ហ៊ួន មានកូន០៣នាក់ ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។ (ក្រៅឃុំ)

-ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

៣-ឈ្មោះ [redacted] មុន្នី ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ មុខរបរសន្តិសុខនិងអនុប្រធានសហជីពឯករាជ្យ ការពារកម្មករនៃក្រុមហ៊ុនហ្វីនិក ស៊ីឃ្យូរីធី ស៊ីស្ទឹម សាសនាព្រះពុទ្ធ ទីកន្លែងកំណើត[redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្នផ្ទះជួលគ្មានលេខផ្លូវ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប៊ុច "រស់" ម្តាយឈ្មោះ [redacted] ស៊ីនឿន "រស់" ប្រពន្ធឈ្មោះ [redacted] ស្រី មានកូន០៧នាក់ ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។ (ក្រៅឃុំ)

-ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ជាប់ចោទពីបទ ៖ **ក្លែងបន្លំឯកសារ និងប្រើប្រាស់លិខិតក្លែង** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងថ្ងៃទី១៣ និងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើស ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៦២៦, មាត្រា ៦២៧, និង មាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសី ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិស្ពានដែក ឃុំធ្លកវៀន ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

<u>អត្ថហេតុនៃរឿងមានដូចតទៅ</u>

កាលពីអំឡុងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ឈ្មោះ [redacted] ប៊ូរិន ភេទប្រុស អាយុ៥៤ឆ្នាំ , ឈ្មោះ [redacted] មុន្នី ភេទប្រុស អាយុ៥២ឆ្នាំ និងឈ្មោះ [redacted] អេងសួ ភេទប្រុស អាយុ៤០ឆ្នាំ បានរៀបចំលិខិតស្នើសុំជួយអន្តរាគមន៍ដើម្បីជួនសាយភន្ត្រាន ដោះស្រាយវិវាទការងារគោលបំណងប្តឹងតតាំងនឹងក្រុមហ៊ុនហ្វីនិកស៊ីឃ្យូរីធីស៊ីស្ទឹមអំពីរឿងវិវាទការងារដោយនៅក្នុងលិខិតនោះបានដាក់បញ្ចូលឈ្មោះ [redacted] ពិសី ជាជនរងគ្រោះរួមទាំងក្លែងស្នាមមេដៃរបស់ជនរងគ្រោះនៅក្នុងលិខិតខាងលើនោះទៀតផង ។ ក្រោយមកជនរងគ្រោះបានដឹងរឿងខាងលើហើយក៏មិនមានបំណងប្តឹងតវ៉ាជាមួយក្រុមហ៊ុនហ្វីនិកស៊ីឃ្យូរីធីស៊ីស្ទឹម ហើយក៏មិនបានចូលរួមធ្វើលិខិតខាងលើជាមួយឈ្មោះ [redacted] ប៊ូរិន, ឈ្មោះ [redacted] មុន្នី និងឈ្មោះ [redacted] អេងសួ នោះទេ ទើបជនរងគ្រោះដាក់ពាក្យបណ្តឹងទៅការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាលតែម្តង ។

-បានឃើញ រាជការណ៍សំយោគលេខ ២៨៨របក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ របស់ការិយាល័យនគរបាលកំរិតស្រាលនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣០២៥ អយជ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ៣៧៨០ អយជ ចុះថ្ងៃ២៨ ខែតុលា ឆ្នាំ២០២១ ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៥១៣៤ "ប"ដដ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] **ប៊ូរិន** បានឆ្លើយថា៖ ខ្ញុំមិនទទួលស្គាល់ការចោទប្រកាន់នោះទេ ។ ខ្លួនមានតួនាទីជាសន្តិសុខនៅក្រុមហ៊ុនហ្វីនិកស៊ីឃ្យូរីធីស៊ីស្ទឹម និងជាប្រធានសហជីពទៀតផង ដោយមានឈ្មោះ [redacted] មុន្នី ជាអនុប្រធាន និងឈ្មោះ [redacted] អេងសួ ជាលេខាធិការ ។ នៅក្នុងអំឡុងខែកុម្ភៈ ឆ្នាំ២០២១ ក្រុមហ៊ុនបានកាត់ប្រាក់ខែបុគ្គលិកដោយគ្មានមូលហេតុនិងមិនបានគិតប្រាក់អតីតភាពការងារដូចនេះពួកខ្លួនបានរៀបចំពាក្យសុំជួយអន្តរាគមន៍ទៅក្រសួងការងារដោយ

ពេលនោះជាពេលបិទខ្ទប់រាជធានីភ្នំពេញនោះពេលខ្ញុំផ្តិតមេដៃលើលិខិតសុំជួយអន្តរាគមន៍នោះហើយខ្ញុំបានប្រគល់លិខិតនោះឱ្យ ឈ្មោះ [redacted] ពិសី បន្តទៀតដោយខ្ញុំពុំដឹងថាអ្នកណាជាអ្នកក្លែងស្នាមមេដៃរបស់ឈ្មោះ [redacted] ពិសី នោះទេ ។ ខ្ញុំទើបតែដឹងថាឈ្មោះ [redacted] អេងសួ ជាអ្នកក្លែងស្នាមមេដៃរបស់ឈ្មោះ [redacted] ពិសី នៅពេលគេចាប់ពួកខ្ញុំបញ្ជូនទៅសមត្ថកិច្ច ដោយខ្ញុំបានលឺឈ្មោះ [redacted] អេងសួ និយាយទូរស័ព្ទជាមួយឈ្មោះ [redacted] ពិសី ថាហេតុអីអ្នកឯងប្តឹងខ្ញុំបើអ្នកឯងជាអ្នកឱ្យខ្ញុំផ្តិតមេដៃឱ្យ ។ ពេលខ្ញុំផ្តិតមេដៃលើលិខិតសុំជួយអន្តរាគមន៍នោះគឺខ្ញុំផ្តិតមេដៃមុនគេទើបបញ្ជូនទៅឱ្យអ្នកផ្សេងទៀត ។ សព្វថ្ងៃវិវាទការងារនេះបានដោះស្រាយចប់រួចរាល់ហើយតាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាលដោយក្រុមហ៊ុនព្រមសងលុយពួកខ្ញុំ ។ សហជីពឯករាជ្យការពារកម្មករគឺខ្ញុំជាប្រធានសហជីពនៅខែមិថុនា ។ ឈ្មោះ [redacted] អេងសួ ពីមុនជាហិរញ្ញិករបស់ក្រុមហ៊ុនតែគាត់ឈប់ធ្វើការក្រោយពេលក្រុមហ៊ុនធ្វើទុក្ខបុគ្គលិកចាស់ៗ ។ ខ្ញុំមិនបានផ្តិតមេដៃជំនួសឈ្មោះ [redacted] ពិសី នោះទេគឺឈ្មោះ [redacted] អេងសួ ជាអ្នកផ្តិតមេដៃជំនួស ។ សមាគមខ្ញុំមានសមាជិកចំនួន១០នាក់ដោយមានការទទួលស្គាល់ពីក្រសួងការងារ។ ខ្ញុំបានដាក់ពាក្យបណ្តឹងទៅក្រសួងការងារហើយប្តឹងដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោយសម្រេចឱ្យខាងកម្មកររឈ្នះក្រោយមកទើបក្រុមហ៊ុនប្តឹងក្រុមហ៊ុនមិនបើកប្រាក់ខែឱ្យបុគ្គលិក ។

-មេធាវី [redacted] បានសន្និដ្ឋាននៅរំឡងថ្ងៃទី១៣.០២.២០២១ កូនក្តីខ្ញុំបានដឹងជនជាប់ចោទទាំងបីនាក់បានដាក់ពាក្យសុំអន្តរាគមន៍ទៅក្រុមហ៊ុន ហើយពេលនោះទើបកូនក្តីខ្ញុំដឹងថាមានស្នាមមេដៃគាត់ ។ ការបង្កើតសហជីពគឺពុំមានលិខិតអនុញ្ញាតពីក្រុមហ៊ុនFINEX ដោយទើបតែដឹងពេលមានលិខិតពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ កូនក្តីខ្ញុំពុំដឹងថាមានសហជីពក្នុងក្រុមហ៊ុននោះទេ ។ បន្តាប់ពីមានរឿងហើយក្រុមហ៊ុនហៅសួរនាំទើបកូនក្តីខ្ញុំបានដឹង ។ កូនក្តីខ្ញុំពុំដែលទាមទារផលប្រយោជន៍របស់ក្រុមហ៊ុននោះទេ ។ ការបង្កើតសហជីពដើម្បីតែប្រយោជន៍បុគ្គលនោះទេហើយក៏ពុំមានឯកសារណាបញ្ជាក់ថាជនជាប់ចោទបានចែកផលប្រយោជន៍ដល់កម្មករនោះដែរ ។ ដូចនេះសុំរក្សាការទាមទារដូចក្នុងពាក្យបណ្តឹង ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានឃើញថាជនជាប់ចោទបានធ្លើយបដិសេធប៉ុន្តែពុំមានភស្តុតាងដោះបន្ទុកនោះទេ ដូចនេះសុំតម្កល់បទចោទដូចក្នុងដីកាសន្និដ្ឋានស្តាពរ និងសុំឱ្យចៅក្រមពិចារណាតាមច្បាប់ ។

-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានថាគោលបំណងរបស់ពួកគាត់គឺបង្កើតសហជីពហើយស្នើសុំទៅក្រសួងការងារដោយមានបុគ្គលិកលើសពី៨នាក់នោះមានសិទ្ធិបើកសហជីព ដោះការលើកឡើងរបស់មេធាវីគឺមិនត្រឹមត្រូវនោះទេ ។ ក្នុងរឿងនេះមានតែឈ្មោះ [redacted] អេងសួ ផ្តិតមេដៃជំនួសឈ្មោះ [redacted] ពិសី ដោយមានការអនុញ្ញាតពីឈ្មោះ [redacted] ពិសី នោះពួកគាត់គ្មានចេតនាប្រព្រឹត្តនោះគ្មានបទល្មើស ហើយគ្មានប៉ះពាល់ដល់ប្រយោជន៍របស់ឈ្មោះ [redacted] ពិសី នោះទេ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យកម្មកររឈ្នះ ។ ដូចនេះសុំឱ្យកូនក្តីខ្ញុំរួចផុតបទចោទ ។

-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានខ្ញុំឯកភាពតាមសហភាគា ។

-ជនជាប់ចោទឈ្មោះ [redacted] ឫទិន សំណូមពរឱ្យតុលាការជួយចំលាក់បទចោទប្រកាន់លើពួកខ្ញុំទាំងបីនាក់ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ឫទិន

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារនានាក្នុងសំណុំរឿង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>យល់ឃើញថា</u>

-កាលពីអំឡុងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ពិតជាមានករណី **ក្លែងបន្លំ និងប្រើប្រាស់ឯកសារក្លែង** មួយបានកើតឡើងនៅរាជធានីភ្នំពេញ ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted]អេងសួ ភេទប្រុស អាយុ៥០ឆ្នាំ, ឈ្មោះ [redacted]ឫទ្ធិន ភេទប្រុស អាយុ៥៤ឆ្នាំ និងឈ្មោះ [redacted]មុន្នី ភេទប្រុស អាយុ៥៣ឆ្នាំ បានធ្វើការក្លែងស្នាមមេដៃរបស់ឈ្មោះ [redacted] ពិសី នៅក្នុងលិខិតស្នើសុំជួយអន្តរាគមន៍ទៅក្រសួងការងារប្រាកដមែន ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឫទ្ធិន** គឺបដិសេធថាខ្លួនពុំបានក្លែងស្នាមមេដៃរបស់ឈ្មោះ ឆោម ពិសី នោះទេ ហើយក៏ពុំដឹងថាឈ្មោះ [redacted]អេងសួ បានក្លែងស្នាមមេដៃរបស់ឈ្មោះ [redacted]ពិសី ដែរ គឺទើបតែដឹងពេលសមត្ថកិច្ចចាប់ឃាត់ខ្លួន។ ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទរូបនេះឆ្លើយថាពេលកន្លងមកគឺបានបញ្ជាក់ថាខ្លួនជាប្រធានសហជីពនិងជាអ្នករៀបចំលិខិតស្នើសុំជួយអន្តរាគមន៍បញ្ជូនទៅក្រសួងការងារដោយមានស្នាមមេដៃរបស់ឈ្មោះ [redacted]ពិសី ទៀតផង។ ដូចនេះការឆ្លើយបដិសេធរបស់ជនជាប់ចោទរូបនេះគឺគ្រាន់តែជាចម្លើយដោះសារដើម្បីរួចផុតពីការចោទប្រកាន់ប៉ុណ្ណោះ ពុំអាចឱ្យតុលាការជឿជាក់បានឡើយ ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] មុន្នី បានឆ្លើយថាខ្លួនសុំបដិសេធការប្តឹងចោទប្រកាន់ពីព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ នៅក្នុងក្រុមហ៊ុនខ្លួនជាមេតំបន់១ និងតំបន់២ និងជាអនុប្រធានសហជីពក្នុងក្រុមហ៊ុន ហើយក្រុមការងារសហជីពក៏មានតែពានាក់គឺខ្លួនជាអនុប្រធាន , [redacted]ឫទ្ធិន ជាប្រធាន និងឈ្មោះ [redacted] អេងសួ ជាលេខាធិការ ។ ក្នុងអំឡុងខែកុម្ភៈ ឆ្នាំ២០២១ ក្រុមកាងារសហជីពរបស់ខ្លួនដោយមានឈ្មោះ [redacted] ឫទ្ធិន បានរៀបចំលិខិតស្នើសុំជួយអន្តរាគមន៍តែការផ្តិតមេដៃប៉ុន្មាននាក់គឺខ្លួនពុំចាំនោះទេ បន្ទាប់ពីខ្លួនផ្តិតមេដៃលើលិខិតនោះរួចហើយខ្លួនបានប្រគល់ឱ្យឈ្មោះ [redacted] អេងសួ បន្តទៀតដើម្បីឱ្យឈ្មោះ [redacted] ពិសី ផ្តិតមេដៃ ហើយពេលឈ្មោះ [redacted] ពិសី បានប្រាប់ឈ្មោះហើយ [redacted]អេងសួ ផ្តិតមេដៃជំនួសទៅគ្មានបញ្ហាអ្វីទេ ហើយពេលនោះឈ្មោះ [redacted] អេងសួ បានផ្តិតមេដៃជំនួសឆោម ពិសី និងលិខិតសេចក្តីថ្លែងការណ៍ស្តីពីគោលបំណងចុះថ្ងៃទី១មិនចាំខែកុម្ភៈ ឆ្នាំ២០២១ បន្ទាប់មកឈ្មោះ [redacted] ឫទ្ធិន ជាអ្នករៀបចំចាត់ចែងបញ្ជូនលិខិតនោះយកទៅក្រសួងការងារជួយដោះស្រាយបញ្ហាកម្មករនិយោជិតកាត់ប្រាក់មេតំបន់រហូត ។ រឿងនេះក្រុមហ៊ុនបានដោះស្រាយចប់សព្វគ្រប់ហើយ ខ្លួនពុំដឹងថាលិខិតទាំងពីរនេះជាលិខិតក្លែងក្លាយនោះទេ ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] អេងសួ បានឆ្លើយថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ នៅក្នុងក្រុមហ៊ុនគឺខ្លួនជាមេតំបន់៤ និងជាលេខធិការសហជីពក្នុងក្រុមហ៊ុន ក្រុមការងារសហជីពមានតែពានាក់គឺខ្លួនជាអនុប្រធាន , ឈ្មោះ [redacted] ឫទ្ធិន ជាប្រធាន និងឈ្មោះ [redacted] មុន្នី ជាអនុប្រធានលេខាធិការ ។ ក្នុងអំឡុងខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហជីពរបស់ខ្លួនគឺឈ្មោះ [redacted] ឫទ្ធិន បានរៀបចំធ្វើលិខិតស្នើសុំជួយអន្តរាគមន៍ ចុះថ្ងៃទីមិនចាំ ខែកុម្ភៈ ឆ្នាំ២០២១ ពិតមែន ហើយចំពោះស្នាមមេដៃលើឈ្មោះ [redacted] ពិសី ខ្លួនពិតជាបានផ្តិតជំនួសគាត់មែនដោយសារខ្លួនបានទូរស័ព្ទទៅ

ឈ្មោះ [redacted] ពិសី ឱ្យមកផ្តិតមេដៃ តែឈ្មោះ [redacted] ពិសី ថាមកពុំបានទេខាងអោងចក្រជាប់ការងារ ហើយឱ្យខ្លួនផ្តិតមេដៃជំនួសចាំមានរឿងអ្វីគេទទួលខុសត្រូវ បន្ទាប់ពីធ្វើលិខិតទាំងពីរនេះរួចហើយ ឈ្មោះ [redacted] ប៊ូរិន បានយកឯកសារនេះទៅដាក់នៅក្រសួងការងារដោះស្រាយលើរឿងកាត់ប្រាក់ខែកម្មករ ហើយរឿងជម្លោះនេះគឺបានដោះស្រាយចប់សព្វគ្រប់ហើយ ។ ស្រាប់តែពេលមានរឿងឈ្មោះ [redacted] ពិសី ថាមិនដឹងរឿងទៅវិញ ហើយសព្វថ្ងៃឈ្មោះ [redacted] ពិសី បានឈប់ពីការងារសហជីព ហើយចំពោះការដោះស្រាយគឺដើម្បីផលប្រយោជន៍រួម ហើយខាងក្រុមហ៊ុនពិតជាមានកាត់ប្រាក់ខែកម្មករប្រាកដមែន ។

-តាមពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ពិសី គឺបានរៀបរាប់ថាកាលអំឡុងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ឈ្មោះ [redacted] ប៊ូរិន, ឈ្មោះ [redacted] អេងសួ និងឈ្មោះ [redacted] មុន្នី បានរៀបចំលិខិតស្នើសុំជួយអន្តរាគមន៍ដើម្បីដាក់ជូននាយកដ្ឋានដោះស្រាយវិវាទការងារក្នុងគោលបំណងប្តឹងតតាំងនឹងក្រុមហ៊ុនហ្វីនិកស៊ុយយ៉ូរីធីស៊ីស្ទឹម អំពីរឿងវិវាទការងារ ។ ក្នុងលិខិតនោះអ្នកទាំងបីបានដាក់បញ្ចូលឈ្មោះខ្លួនរួមទាំងមានរៀបចំបង្កើតជាស្នាមមេដៃរបស់ខ្លួននៅក្នុងលិខិតនោះទៀតផង ។ ខ្លួនមិនដែលមានបំណងប្តឹងតវ៉ាអ្វីនឹងក្រុមហ៊ុននោះទេ ហើយខ្លួនក៏មិនដែលបានចូលរួមក្នុងការធ្វើលិខិតទាំងអស់នោះដែរ ទើបតែពេលថ្មីៗនេះទើបខ្លួនដឹងថាអ្នកទាំងពីរនេះបានប្រើប្រាស់ឈ្មោះខ្លួនរួមទាំងក្លែងបន្លំស្នាមមេដៃរបស់ខ្លួនដើម្បីយកទៅប្រើប្រាស់ជាផលប្រយោជន៍ក្រុមខ្លួនឯងទៅវិញ ។ ហើយនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ អ្នកទាំងពីរនាក់នេះថែមទាំងលួចក្លែងហត្ថលេខារបស់ខ្លួនដើម្បីយកទៅបង្កើតសហជីពដែលមានឈ្មោះថា សហជីពឯករាជ្យការពារកម្មករនៃក្រុមហ៊ុនហ្វីនិក ស៊ុយយ៉ូរីធី ស៊ីស្ទឹម ថែមទៀតផង ។ ទង្វើខាងលើនេះធ្វើឱ្យខ្លួនបាត់បង់ផលប្រយោជន៍ជាច្រើនរួមទាំងបំពានសិទ្ធិរបស់ខ្លួនថែមទៀតផងព្រោះខ្លួនមិនដែលមានវិវាទជាមួយក្រុមហ៊ុនោះទេ ។ ដូចនេះខ្លួនសុំទាមទារសំណងជម្ងឺចិត្តចំនួន ៥០០០០ដុល្លារអាមេរិក និងសេវាកម្មផ្លូវច្បាប់ចំនួន ២០០០០ដុល្លារអាមេរិក ។

-តាមចម្លើយរបស់ជនជាប់ចោទទាំងបីនាក់ និងពាក្យបណ្តឹងរបស់ដើមបណ្តឹងឃើញថាជនជាប់ចោទឈ្មោះ [redacted] អេងសួ ពិតជាបានក្លែងស្នាមមេដៃនិងហត្ថលេខារបស់ដើមបណ្តឹងឈ្មោះ [redacted] ពិសី នៅក្នុងលិខិតស្នើសុំជួយអន្តរាគមន៍ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ និងសេចក្តីថ្លែងការណ៍ស្តីពីគោលបំណង ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ ប្រាកដមែន ។ ចំណែកឈ្មោះ [redacted] ប៊ូរិន ដែលជាប្រធានសហជីព និងឈ្មោះ [redacted] មុន្នី ដែលជាលេខាធិការ ក៏បានដឹងថាឈ្មោះ [redacted] អេងសួ ជាអ្នកផ្តិតមេដៃ និងហត្ថលេខាជំនួសដើមបណ្តឹងដែរ ប៉ុន្តែដើម្បីផលប្រយោជន៍របស់ពួកខ្លួនជនជាប់ចោទទាំងបីនាក់ក៏ប្រើប្រាស់លិខិតទាំងពីរនោះដើម្បីស្នើទៅក្រសួងការងារ ។ នោះឃើញថាចម្លើយបដិសេធរបស់ជនជាប់ចោទទាំងបីនាក់គឺគ្រាន់តែជាចម្លើយដោះសារដើម្បីរួចផុតពីការចោទប្រកាន់ប៉ុណ្ណោះ ព្រោះគ្មានភស្តុតាងណាមកបញ្ជាក់នោះទេ ដូចនេះមិនអាចឱ្យតុលាការជឿជាក់បានឡើយ ។

-តាមចម្លើយជនជាប់ចោទទាំងបីនាក់ ចម្លើយដើមបណ្តឹង និងការពិនិត្យភស្តុតាងឃើញថាគឺមានតែជនជាប់ចោទឈ្មោះ [redacted] អេងសួ ម្នាក់ទេដែលជាអ្នកក្លែងស្នាមមេដៃ និងហត្ថលេខារបស់ដើមបណ្តឹង ចំណែកជនជាប់ចោទឈ្មោះ ពេជ្រ ប៊ូរិន និងឈ្មោះ [redacted] មុន្នី គ្រាន់តែបានដឹងលឺពីការក្លែងស្នាមមេដៃនិងយកឯកសារទាំងនេះទៅប្រើប្រាស់ដើម្បីប្រយោជន៍ពួកគេ ។ ដូចនេះគប្បីធ្វើការកែប្រែចោទប្រកាន់លើឈ្មោះ [redacted] ប៊ូរិន និងឈ្មោះ [redacted] មុន្នី ពីបទ ក្លែងបន្លំ មកបទ សមគំនិតក្នុងអំពើក្លែងបន្លំ ។

-មានភាពស៊ីសង្វាក់គ្នារវាងចម្លើយរបស់ជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងតាមការពិនិត្យឯកសារជាភស្តុតាងផ្សេងៗទៀតក្នុងសំណុំរឿងអាចឱ្យតុលាការកំណត់បាននៅថ្ងៃទី១៣ និងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] **អេងសួ** ភេទប្រុស អាយុ៤០ឆ្នាំ ពិតជាបានក្លែងបន្ធំស្នាមមេដៃ និងហត្ថលេខារបស់ដើមបណ្តឹងឈ្មោះ [redacted] ពិសី នៅក្នុងលិខិតស្នើសុំជួយអន្តរាគមន៍ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ និងសេចក្តីថ្លែងការណ៍ស្តីពីគោលបំណង ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ ដោយមានការចូលរួមដឹងលឺពីជនជាប់ចោទឈ្មោះ [redacted] **ប៊ូរិន** ភេទប្រុស អាយុ៥៤ឆ្នាំ និងឈ្មោះ សៅ **មុន្នី** ភេទប្រុស អាយុ៥៣ឆ្នាំ ដើម្បីឱ្យមានអានុភាពធ្វើជាភស្តុតាងនៃសិទ្ធិប្រាកដមែន ហើយជនជាប់ចោទទាំងបីនាក់នេះក៏បានប្រើប្រាស់លិខិតទាំងពីរច្បាប់នេះដើម្បីស្នើសុំទៅក្រសួងការងារទៀតផង ។ អំពើទាំងនេះច្បាប់បានកំណត់ជាបទល្មើស **ក្លែងបន្ធំ , សមគំនិតក្នុងអំពើក្លែងបន្ធំ និងប្រើប្រាស់លិខិតក្លែង** ដោយមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦២៦, ៦២៧ និង ៦២៨ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] **ប៊ូរិន**, ឈ្មោះ [redacted] **អេងសួ** និងឈ្មោះ [redacted] **មុន្នី** ជានីតិជនដែលមានឥតិសម្បទាគ្រប់គ្រាន់ដោយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថាជននេះមានវិបល្លាសស្មារតីកើតចេញពីអំពើរបស់ខ្លួនដែលស្ថិតក្នុងលក្ខខណ្ឌនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ហេតុនេះត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន ។

-មានភស្តុតាង ពិរុទ្ធភាព និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ៖

១-ឈ្មោះ [redacted] **អេងសួ** ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរសន្តិសុខនិងលេខាធិការសហជីពឯករាជ្យការពារកម្មករនៃក្រុមហ៊ុនហ្វីនិក ស៊ីឃ្យូរីធី ស៊ីស្ទឹម សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិកោះខ្ពត ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅបច្ចុប្បន្នផ្ទះលេខ៥២ ផ្លូវលេខ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប៊ុន "រស់" ម្តាយឈ្មោះ [redacted] ចាន់ថន "រស់" នៅលីវ ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។

ជាប់ចោទពីបទ ៖ **ក្លែងបន្ធំ និងប្រើប្រាស់លិខិតក្លែង** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងថ្ងៃទី១៣និងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើស ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៦២៦, មាត្រា ៦២៧, និងមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ។

២-ឈ្មោះ [redacted] **ប៊ូរិន** ភេទប្រុស អាយុ៥៤ឆ្នាំ ជនជាតិខ្មែរ មុខរបរសន្តិសុខនិងប្រធានសហជីពឯករាជ្យការពារកម្មករនៃក្រុមហ៊ុនហ្វីនិក ស៊ីឃ្យូរីធី ស៊ីស្ទឹម សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិសាមគ្គី ឃុំសាមគ្គី ស្រុកពាមជ ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នផ្ទះលេខ២តេ ផ្លូវលំ ភូមិជម្ពូវ័ន្ត សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឆាំ "រស់" ម្តាយឈ្មោះ [redacted] សុខ "រស់" ប្រពន្ធឈ្មោះ សេក ហ៊ួន មានកូន០៣នាក់ ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។

៣-ឈ្មោះ [redacted] **មុន្នី** ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ មុខរបរសន្តិសុខនិងអនុប្រធានសហជីពឯករាជ្យការពារកម្មករនៃក្រុមហ៊ុនហ្វីនិក ស៊ីឃ្យូរីធី ស៊ីស្ទឹម សាសនាព្រះពុទ្ធ ទីកន្លែងកំណើត [redacted] ខេត្តកំពត ទីលំនៅបច្ចុប្បន្នផ្ទះជួលគ្មានលេខផ្លូវ២០០២ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ

រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ប៊ុច "រស់" ម្តាយឈ្មោះ [redacted] ស៊ីនឿន "រស់" ប្រពន្ធឈ្មោះ [redacted] ស្រី មានកូន០៧នាក់ ជាពលរដ្ឋ ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន។

ជាប់ចោទពីបទ ៖ **សមគំនិតក្នុងអំពើក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងថ្ងៃទី១៣និងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើស ដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩, មាត្រា៦២០, មាត្រា ៦២៧, និងមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ។

-តាមសេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] គឺកូនក្តីខ្លួនដឹងថាមានស្នាមមេដៃគាត់នៅពេលជនជាប់ចោទទាំងបីនាក់បានដាក់ពាក្យសុំអន្តរាគមន៍ទៅក្រុមហ៊ុន ។ ការបង្កើតសហជីពគឺពុំមានលិខិតអនុញ្ញាតពីក្រុមហ៊ុនFINEX ដោយទើបតែដឹងពេលមានលិខិតពីក្រុមហ៊ុនប្រឹក្សាអាជ្ញាកណ្តាល ។ កូនក្តីខ្លួនពុំដឹងថាមានសហជីពក្នុងក្រុមហ៊ុននោះទេ បន្ទាប់ពីមានរឿងហើយក្រុមហ៊ុនហៅសួរនាំទើបកូនក្តីខ្លួនបានដឹង កូនក្តីខ្លួនពុំដែលទាមទារផលប្រយោជន៍របស់ក្រុមហ៊ុននោះទេ ។ ការបង្កើតសហជីពដើម្បីតែប្រយោជន៍បុគ្គលនោះទេហើយក៏ពុំមានឯកសារណាបញ្ជាក់ថាជនជាប់ចោទបានចែកផលប្រយោជន៍ដល់កម្មករនោះទេ ។ ដូចនេះសុំរក្សាការទាមទារដូចក្នុងពាក្យបណ្តឹងគឺសំណងជម្ងឺចិត្តចំនួន ៥០០០ ដុល្លារអាមេរិក និងសេវាកម្មផ្លូវច្បាប់ចំនួន ៣០០០០ដុល្លារអាមេរិក ។ ដូចនេះគប្បីតុលាការលើកយកមកពិចារណាតាមច្បាប់ ។

-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការគឺជនជាប់ចោទបានធ្លើយបដិសេធប៉ុន្តែពុំមានភស្តុតាងដោះបន្ទុកនោះទេ ដូចនេះសុំតម្កល់បទចោទដូចក្នុងដីកាសន្និដ្ឋានស្តាពរ និងសុំឲ្យចៅក្រមពិចារណាតាមច្បាប់ ។ ឃើញថាមានភស្តុតាងគ្រប់គ្រាន់ ដូចនេះគប្បីតុលាការពិចារណាតាមច្បាប់ ។

-តាមសេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] គឺគោលបំណងរបស់ពួកគាត់គឺបង្កើតសហជីពហើយស្នើសុំទៅក្រសួងការងារដោយមានបុគ្គលិកលើសពី៨នាក់នោះមានសិទ្ធិបើកសហជីព នោះការលើកឡើងរបស់មេធាវីគឺបិនត្រឹមត្រូវនោះទេ ។ ក្នុងរឿងនេះមានតែឈ្មោះ [redacted] អេងសួ ផ្តិតមេដៃជំទួសឈ្មោះ [redacted] ពិសី ដោយមានការអនុញ្ញាតពីឈ្មោះ [redacted] ពិសី នោះពួកគាត់គ្មានចេតនាប្រព្រឹត្តនោះគ្មានបទល្មើស ហើយមិនប៉ះពាល់ដល់ប្រយោជន៍របស់ឈ្មោះ [redacted] ពិសី នោះទេ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលឲ្យកម្មករឈ្នះ ដូចនេះសុំឲ្យកូនក្តីខ្លួនរួចផុតបទចោទ ។ តុលាការឃើញថាពុំមានភស្តុតាងគ្រប់គ្រាន់នោះទេ នោះគប្បីតុលាការមិនលើកយកមកពិចារណាឡើយ ។

-ជនជាប់ចោទឈ្មោះ [redacted] **ឃួរិន** បានសំណូមពរឲ្យតុលាការជួយលើកលែងការចោទប្រកាន់ ប៉ុន្តែគ្មានភស្តុតាងណាមកបញ្ជាក់នោះទេ ដូចនេះតុលាការនឹងពិចារណាតាមច្បាប់ ។

<u>ហេតុផ្តើមចេះសម្រេច</u>

១.កែប្រែបទចោទលើឈ្មោះ [redacted] **ឃួរិន** ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **មុន្នី** ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ ពីបទ **ក្លែងបន្លំ** បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ មកបទ **សមគំនិតក្នុងអំពើក្លែងបន្លំ** បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩, មាត្រា៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ ។

២.ផ្តន្ទាទោសលើជនជាប់ចោទ៖

ក.ឈ្មោះ [redacted]អេងសួ ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០២(ពីរ)ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសក្នុងពន្ធនាគារគិតពីថ្ងៃឃុំខ្លួនរហូតដល់ថ្ងៃដោះលែងឱ្យនៅក្រៅឃុំ ទោសសល់ពីនេះត្រូវព្យួរធម្មតា ។

ពីបទ ៖ **ក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងថ្ងៃទី១៣និងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៦២៦, មាត្រា ៦២៧, មាត្រា៦២៨ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

ខ.ឈ្មោះ [redacted]ឫទ្ធិ ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០២(ពីរ)ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសក្នុងពន្ធនាគារគិតពីថ្ងៃឃុំខ្លួនរហូតដល់ថ្ងៃដោះលែងឱ្យនៅក្រៅឃុំ ទោសសល់ពីនេះត្រូវព្យួរធម្មតា ។

គ.ឈ្មោះ [redacted]មុន្នី ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០២(ពីរ)ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសក្នុងពន្ធនាគារគិតពីថ្ងៃឃុំខ្លួនរហូតដល់ថ្ងៃដោះលែងឱ្យនៅក្រៅឃុំ ទោសសល់ពីនេះត្រូវព្យួរធម្មតា ។

ពីបទ ៖ **សមគំនិតក្នុងអំពើក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងថ្ងៃទី១៣និងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើស ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៩, មាត្រា៦២៦, មាត្រា ៦២៧, មាត្រា៦២៨ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

៣.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted]អេងសួ, ឈ្មោះ [redacted]ឫទ្ធិ និងឈ្មោះ [redacted]មុន្នី រួមគ្នាសងសំណងជម្ងឺចិត្ត និងសោកម្មផ្លូវច្បាប់សរុបចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ពិសី ។ ការទាមទារលើសពីនេះបដិសេធចោល ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ឫទ្ធិ, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]អេងសួ និងឈ្មោះ [redacted]មុន្នី និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា៖ [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា៖ [redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២

ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]